មន្ត្រីទី ២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

- យោងព្រះរាជក្រឹត្យ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៅតាមក្រសួង ស្ថាប័ន និងរដ្ឋលេខាធិការដ្ឋាន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** អនុញ្ញាតឱ្យ ឯកឧត្តម **ខៀវ វ៉ាដា** លាលែងចេញពីមុខដំណែង ជាអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

* * *

# II - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ : ០៩ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង**

**ពិនិត្យទាយតំលៃទៀសរើសឈើគីរោងការ**

**បូមដី បាតទន្លេ—ស្ទឹង ព្រែក និង បឹង**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ លេខ ១០៩៤-៨៣ នស/រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤-៩០ នស.រកត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណូមពរចាំបាច់នៃការងារ

**សំរេច**

**មាត្រា ១** : បង្កើតគណៈកម្មការអន្តរក្រសួងមួយទទួលបន្ទុកការងារពិនិត្យ សិក្សាវាយតំលៃជ្រើសរើសលើកយោបល់ជូននាយករដ្ឋមន្ត្រីទាំងពីរសំរេច លើគំរោងការបូមដីបាតទន្លេ-ស្ទឹង , ព្រែក និង បឹង ។

សមាសភាពគណៈកម្មាធិការនេះមានដូចតទៅ :

- ឯកឧត្តម **ង៉ែត ឡៅ**	ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ជាប្រធាន
- ឯកឧត្តម **សុខ អាន**	សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក
- ឯកឧត្តម **ម៉េង សិរីវុឌ្ឍ**	សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

–ឯកឧត្តម **ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាសមាជិក

–ឯកឧត្តម **ឈឹម សៀកឡេង** ប្រតិភូរាជរដ្ឋាភិបាល ជាសមាជិក

–ឯកឧត្តម **ហេង ចន្ទ្រប៊ុនណាត** តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ជាសមាជិក

–ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក

–ឯកឧត្តម **អ៊ុម ឈុនលឹម** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក

–ឯកឧត្តម **ហ៊ុល លឹម** អនុរដ្ឋលេខាធិការក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ជាសមាជិក

–លោក តំណាងក្រសួងការពារជាតិ ជាសមាជិក

**មាត្រា ២ :** គណៈកម្មការនេះមានភារកិច្ចទទួល និងសិក្សាពិនិត្យលើសំណើសុំ នៃគំរោងការបូមដីចាតទន្លេ ស្ទឹង ព្រែក និងបឹងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រៀបធៀបជ្រើសរើស និង ផ្ទៀងផ្ទាត់លើគំរោង អភិវឌ្ឍន៍តំបន់ផ្សេងៗ និងគំរោងដែលមានស្រាប់ និង ស្នើជាយោបល់ថ្វាយ និងជូននាយករដ្ឋមន្ត្រីសំរេច ។

**មាត្រា ៣ :** ក្រោយពីមានការសំរេចជាគោលការណ៍គណៈកម្មការនេះ មានភារកិច្ចរៀបចំពិនិត្យ លំអិត និងចុះហត្ថលេខាលើកិច្ចសន្យាជាមួយក្រុមហ៊ុន វិនិយោគដែលត្រូវជ្រើសរើសក្នុងនាមរាជរដ្ឋាភិបាល ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |